សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ ថ្ងៃទី៤ ខែមករា ឆ្នាំ២០១១

សម្រាប់ការផ្សព្វផ្សាយជាបន្ទាន់

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានឹងសង្កេតសវនាការជំនុំជម្រះក្តីពាក់ព័ន្ធនឹងភរិយានៃអ្នកជំនួញដែលមានកេរ្តិ៍ឈ្មោះ

នៅថ្ងៃពុធ ទី៥ ខែមករា ឆ្នាំ២០១១ មន្ត្រីសង្កេតការណ៍សវនាការនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា នឹងចូលរួម និងសង្កេតការណ៍សវនាការករណីឈ្មោះសេង ចិន្តា ដែលជាភរិយារបស់លោកឃូវ ជូលី អ្នកជំនួញដ៏មានកេរ្តិ៍ឈ្មោះម្នាក់ និងអ្នកសមគំនិតចំនួន ៤ នាក់ផ្សេងទៀត មានដូចជា ចាន់ សុខា នាង ស៊ីណាត ខន ឡាក់ និងយិន សុភារិទ្ធ នៅឯសាលាដំបូងរាជធានីភ្នំពេញ។ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទឃាតកម្មគិតទុកជាមុនទៅលើកូនស្រីចុងរបស់ខ្លួនឈ្មោះស៊ូវ ចាន់ថា ដែលជាភរិយារបស់លោកស៊ុន ចាន់ថុល អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា និងជាអតីតរដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន។ ប្រសិនបើរកឃើញថាមានទោស ជនជាប់ចោទអាចនឹងត្រូវផ្តន្ទាទោសអតិបរមាដាក់ពន្ធនាគារអស់មួយជីវិត។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា នឹងសង្កេតសវនាការស្របទៅតាមបទដ្ឋានជាតិ និងអន្តរជាតិទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ឧទាហរណ៍ដូចជាការពោលអះអាងរបស់ជនជាប់ចោទម្នាក់នៅក្នុងសវនាការ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ ថាខ្លួនបានផ្តល់ចម្លើយ និងសក្ខីភាព ឲ្យដល់មន្ត្រីនគរបាល ដោយសារការបង្ខិតបង្ខំ។ ការលើកឡើងនេះបង្កឲ្យមានការព្រួយបារម្ភ ជាពិសេសបើប្រៀបធៀបទៅនឹងបទដ្ឋានជាតិ និងអន្តរជាតិទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

ម៉ាង ម៉ូនីកា មន្ត្រីសង្កេតការណ៍សវនាការនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
លេខទូរស័ព្ទ ៖ +៨៥៥ ១៦ ៩២ ៧២ ៧៩
អ៊ីមែល ៖ monika.mang@cchrcambodia.org